## មន្តគាថាប្រើបាន១០០គុណ

តាមតែចិត្តលោកអ្នកសិក្សា ស្រឡាញ់ចូលចិត្តគាថាណាមួយដកយកទៅ

ប្រើចុះ និងបានសំរេចដូចសេចក្តីប្រាថ្នាហោង ។

........................................................

### គាថានេះប្រើបាន ១០០គុណ

ឧមៈកំចាត់ ឧមកំចាយ កំចាត់ទាំងមេជ្រួញអាប ធ្មប់ ឧមៈកំចាយមហាកំចាយ កំចាយទាំងមេ ព្រាយ កំចាយទាំងមេអាប កំរាបទាំងមេធ្មប់ ទើបគ្រូប្រើអញ្ច កំចាត់ក្បាលកាត់ទាំងកយកមកថ្វាយគ្រូ អញ្ច ចរណាចេញទៅ ។(សូត្រ៧ចប់) *ចម្លងតាមក្បួនលោកសួ វង្ស តម្កល់ទុកនៅពុទ្ធសាសនបណ្ឌិត*

គាថាប្រើ ១០០គុណ

ឯហិ ទកសា បិយំមម ឯហិពេជ្ជធាន បិយំមម ឯហិពេជ្ជធាន បិយំមម ឯហិពេជ្ជ ប្រាន បិយំមម ឯហិពេជ្ជប្រាព្វ បិយំមម ។ (សូត្រ៧ចប់)លោកតាព្រះសព ឯក ញឹម វត្តរលួស ខេត្តសៀមរាប (អង្គរ)

គាថាប្រើ ១០០គុណ

ឥតិ អយៈ យន្តំ វតី ករេ ។(សូត្រ៧ចប់)

នមោទ្វាយ នមអឧ សីលវា ពុទ្ធោ១១ ។(សូត្រ៧ចប់) *ចម្លងតាមក្បួន អាចារ្យស្វា*

................................................

### កន្លែងព្រះប្រើ ១០០គុណ

នមោ ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ អរហន្តំ តេជោ សោតា បដិផលាតេជោ រិទ្ធីតេជោ សិទ្ធីតេជោ ជយ ជយោ សព្វសត្រូវ វិនាស្សន្តិ អសេ្សតោ ។(សូត្រ៧ចប់)

ប្រើប្រសិទ្ធីគាថារបៀបសង្ខេប

ពុទ្ធំ ទស្ស សិលំ អធិដ្ឋានមិ ។(សូត្រ៣ចប់) *ចម្លងតាមក្បួនលោកវរសេនីយ៍ទោ នាង ឈុំ*

គាថាមហារំអិលចាប់មិនជាប់

ឱថ រិបិ ប៉ស ឧ ។(សូត្រ៧ចប់) *ចម្លងតាមក្បួនលោក តេជោក្រហម*

គាថាភាវនាដើរ ឬ រត់មិនហត់

*ហិចំងំ នំមំតំ មនចះ ។ លោកតាព្រះសព វត្តក្វាក (បាត់ដំបង)*

គាថាស្រោចទឹកឆ្អែតឆ្អួតខាំ

សុនក្ខោ ខន្ធោ ភិក្ខុ ស្វាហៈ ។(សូត្រ៧ចប់ ពីរដង)

ឱ្យស្រោចទឹកលើក្បាលដំបូក លោកគ្រូ ហ៊ឹង ដល់មាត់ជណ្តើរផ្ទះអ្នកជំងឺ ឱ្យសូត្រ៣ចប់ ។

ដុត្តឹង ដត្តា ធាតឹង តាអុំ រួចធាក់កាំជណ្តើរ៣ជើង ឱ្យអ្នកជំងឺខ្លាច ។ ឡើងដល់លើផ្ទះ សូត្របើកទ្វារចូលទៅ : ឧម: បើក បែក ចែកដី ស្វាហៈ (សូត្រ៣ចប់)

*លោកគ្រូ សមុត វត្តបឹង ខេត្តអង្គររាជ អតីតដែនដីខ្មែរ*

មហាកំរើក

សី ហី គ្រុ ទ្វោ(សូត្រ៩ចប់)

មហាសំឡុត

ឧម: នាគពន្ធំ ព្រះចន្ទខាន់រាយ កម្លាំងអ្នកផងទាំងឡាយ សឹងជុំចុះមកក្នុងព្រះមន្តអញ ទើបអង្គអញវិលវឹងបំបាត់ស្មារតី ភ្វាំ ភ្វាំ ស្វាហៈ ។(សូត្រ ៤ចប់)

*ចម្លងតាមក្បួនលោកគ្រូ ដាន់ វត្តសាលាឡយ ខេត្តសុរិន្ទ អតីតដែនដីខ្មែរ សម័យមហានគរ ។*

គាថាចាក់សោ ការពារ

-ឧម: ពុទ្ធំ មហាពុទ្ធំ ឧម: ពុន្ធំ មហាពុន្ធំ ឧម: គតថេរំ សោយធាយ ។

-សីល នម សិសោ សិល ពុទ្ធោ នមោ ពុទ្ធាយ ម.អ.ឧ ។

(សូត្រ៧ចប់) ចម្លងតាមក្បួនព្រះគ្រូ ម៉ៅ សៀន វត្តអង្គព្រះស្តេច

មន្តអាថាន់ ការពារអំពើ ឬ ធ្មប់

ឱម: សារំ សរាមតេ សរោ អ:ម: ។(សូត្រ៧ចប់) *លោកគ្រូអាចារ្យ យី*

មន្តគាថាប្រើបាន ១០០គុណ

+ឧកាសៈ ឧកាសៈ ខ្ញុំព្រះករុណា សុំអរទ្ធនា អង្គអក្ខរា-អាគមគាថា លេខយ័ន្ត នូវព្រះធម៌ព្រះត្របិដក និងព្រះធម៌វិបស្សនាកម្មដ្ឋានទាំង៨ម៉ឺន៤ពាន់ ព្រះធម្មខន្ធ ។ សូមព្រះអង្គយាងមកគង់សណ្ឋិតឱ្យមូលក្រឡង់ដូចព្រះអាទិត្យ ព្រះច័ន្ទពេញបូរមី សូមរស្មី៦ពណ៌ សូមឈ្នះចិត្តទ្រឹស្តឫស្យា ទមិឡអន្យ តិរត្ថិយ៍កន្លងលែងទុក្ខ កន្លងលែងភ័យអាសន្នអន់ក្រ ។ សូមសុខប្រសើរ ដូចដំណើរដព្រះអង្គហោង ។

+ខដេសិ ខដេសិ កឺ ករុណា ខដេសិ អហម្បិតំ ជានាមិ ជានាមិ ។(សូត្រ៣ចប់ ប្រើគ្រប់ជំពូក)

អំពីឱសថកែរោគផ្សេងៗ

គួរតែយើងចេះចាំខ្លះ

រោគទាស់ : ជើងមាន់ព្រៃ ដុសជាមួយទឹកអង្ករផឹក ពូកែហោង ។

រោគគ្រុនចាញ់ : ដីដំបូកអាំង កំឡោចបាយក្តាំង ទន្ទ្រានខែត្រ ដាំទឹកផឹក ពូកែណាស់ហោង។

*ចម្លងតាមក្បួនព្រះគ្រូ ថាច់ ឈូក*

ឱសថកែរោគស្វាយក្រាប ស្វាយបែក និងប្រមេះ

ថ្នាំត្រាំស្រា ឬ ដាំទឹកផឹក

សំបកស្តុកស្តុល (ហាលក្រៀម) ដើមវល្លិ៍គុយ (ហាលក្រៀម)ឫសរំចេក (ហាលក្រៀម) គល់ ដើមម្នាស់ (ហាលក្រៀម)ដើមវល្លិ៍ក្រទ្បើតចក (ហាលក្រៀម) ពស់ខ្សែគោ១តៃសាក (អាំងកំឡោច) គីង្គក់ពីរតៃសាក (អាំងកំឡោច)ស្រា១លីត្រ ឬដាំទឹកផឹក ។

របៀបប្រើ

ព្រឹកពិសា ១ពែងតូច , ល្ងាច១ពែងតូច ។ពិសាអស់១លីត្រ ឬ២លីត្រជាហោង។*លោកគ្រូអុំជួន*

អំពីឱសថកែរោគហឺត និងស្គមរីងរៃ ក្តៅស៊ិញ

ឱសថនេះខ្ញុំបានដកស្រង់ចេញពីសៀវភៅ "គុកនយោបាយ"របស់លោក បុណ្ណ ចាន់ម៉ុល ត្រង់ ទំព័រលេខ ១៩៦-១៩៧ ដែលអ្នកនិពន្ធបានពិសោធឃើញថា ប្រើឱសថនេះទៅច្រើនសមប្រកបដូច បំណង។ ចំណែកឯក្បាលស្វាវិញ គេធ្វើឱ្យស្អាត ហើយគេយកទៅធ្វើបបរជាមួយសណ្តែកបាយ ។លុះ ផុយសណ្តែកបន្តិចហើយ គេយកទៅហាលទឹកសន្សើម១យប់ សម្រាប់ឱ្យមនុស្សកើតរោគហឺតផឹក ឬរីងរៃ ស្គម ក្តៅខ្លួនទទួលទាន ។

លោកបានសង្កេតឃើញមានអ្នករោគទាំងប៉ុន្មានប្រភេទខាងលើនេះ បានជាសះស្បើយ សមប្រ កបបានច្រើនគ្នាមែន ។

ម្យ៉ាងទៀត គេចាប់សត្វតុកកែមួយ ឬ ពីរ វាយឱ្យស្លាប់ គេរោលភ្លើងឱ្យរបកស្បែកក្រៅអស់ គេ ចិញ្ច្រាំសាច់ឱ្យម៉ដ្ឋ ហើយផ្សំគ្រឿងបបរជាមួយអង្ករក្រហម ធ្វើតាមរបៀបយើងធ្វើបបរមាន់ដូច្នោះដែរ។ បបរឱសថនេះទទួលទានទៅស្រួលខ្លួន អាចរំងាប់រោគ ដូចពោលខាងលើនេះ ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

+ឱសថកែរោគហឺតនេះ ខ្ញុំបានយកទៅធ្វើតាមឱ្យកូនប្រុសខ្ញុំម្នាក់អាយុ៦ឆ្នាំ កើតរោគហឺតតាំងពី តូច ញ៉ាំទៅឃើញបានជាស្រួលខ្លួន ដូចប្រាថ្នាមែន ។

## ក្បួនយាមក្រឡា




រូបភាព ទំព័រ ១៣០

*បានចម្លងតាមក្បួនលោក កង សាផាន អ្នកតំណាងរាស្ត្រមណ្ឌលស្រែជា (កំពត) ។*

បូរាណលោកបានចងក្រងជាយាមក្រឡានេះសម្រាប់ប្រើនៅពេលចេញដំណើរយប់ ឬ ថ្ងៃ អ្នកណាប្រព្រឹត្តតាមក្បួននេះមានប្រសិទ្ធភាពណាស់ ។ សូមមើលសេចក្តីពន្យល់ :

ខ្ទង់ចុងក្រឡាខាងស្តាំ និងចំណុច (ពិន្ទុ) ដែលនៅក្នុងក្រឡាខាងឆ្វេង ។ កំណត់ចំណាំ : ក្នុង១ថ្ងៃមានល្អ៣ពេល អាក្រក់២ពេល មុននឹងចេញដំណើរសូមអស់លោកអ្នកប្រកាន់យកតែពេលល្អចុះ នឹងបានជួបសុភមង្គលគ្រប់ប្រការ មិនឃ្លៀងឃ្លាតឡើយ ។

តាមក្បួនតម្រា លោកចារទុកមកពីព្រេងនាយឱ្យជនផងជាទុកតបានវែង ក្បួននេះខ្ញុំតែងជាពាក្យ កាព្យ ។ ថ្ងៃទាំងប្រាំពីរ មួយទិនទេវា លោកបែងចេញជាវេលាមានប្រាំ ពេលបីសោភា ពេលពីរភយា កុំបី ត្រាច់ចរ ។ អាទិត្យយប់ព្រឹក សូន្យបួនពន្លឺក ថ្ងៃត្រង់ផុតសូន្យ រសៀលសូរិយាជួបនឹងពីរសូន្យ តាមក្បួន វាជួន ជួបនឹងលាភា ។ *អំ កេត*

គំនិតត្រិះរិះសម្រាប់ពលរដ្ឋខ្មែរ

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

ដើម្បីនឹងបានជាពលរដ្ឋនៃប្រទេសជាតិដ៏ថ្លៃថ្លា រុងរឿងសមតាមសម័យ ពលរដ្ឋខ្មែរត្រូវមានចំណេះចេះដឹងប្រកបដោយអង្គបី គឺ :

១-សៃយមន្ត -ចេះច្បាប់អ្នកស្រុក

២-រដ្ឋមន្ត -ចេះច្បាប់មន្ត្រី

៣-ពុទ្ធមន្ត -ចេះច្បាប់សាសនា

សៃយមន្តមាន ៤យ៉ាង

១-ត្រៃភូមិ -ចេះមើលពីសណ្ឋានភាពដី មេឃ ផ្កាយ ខ្យល់ ។

២-ត្រៃភេទ -ចេះមើលទស្សទាយក្បួនតម្រាផ្សេងៗ ។

៣-ត្រៃដា -ចេះរបៀបសែនព្រេន ខ្មោចបិសាចគ្រប់ផ្នែក ។

រដ្ឋមន្តមាន ២យ៉ាង

១-ត្រូវចេះច្បាប់ជាតិ មានរដ្ឋធម្មនុញ្ញ ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ជាដើម ។

២-ត្រូវចេះច្បាប់គ្រប់គ្រងប្រទេស ឬច្បាប់លោកនីតិ ។

ពុទ្ធមន្តមាន ៣យ៉ាង

១-ត្រូវចេះព្រះវិន័យ

២-ត្រូវចេះព្រះសូត្រ

*៣-ត្រូវចេះព្រះអភិធម្ម លោកមហា អែល ញ៉ាន់*

គំនិតត្រិះរិះចំពោះអ្នកជំនួញ

ដើម្បីបានទៅជាអ្នកជំនួញពូកែរកទ្រព្យបានច្រើន អ្នកជំនួញខ្មែរយើង ត្រូវចេះលក្ខណៈ បីយ៉ាង គឺ :

១-ទិញឱ្យថោក

២-លក់ឱ្យថ្លៃ

៣-ទុកប្រាក់ឱ្យគង់

ច្បាប់ជំនួញតាមរបៀបពុទ្ធសាសនាមានអង្គ ៤ គឺ

១-ត្រូវចេះស្វែងរកទ្រព្យតាមបច្ចេកទេស

២-រក្សាទ្រព្យទុកឱ្យគង់

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

៣-ស្វែងរកមិត្តឱ្យបានល្អ

៤-ចេះចាយវាយទ្រព្យ តាមដែលខ្លួនអាចរកបាន ។

## នេះហៅមហាសំកោក

នមនមៈ នំកុំនំ កកុំអុំ នំអន អកអ័ មសិតសោ រទំសត្ថអះ ។

ជាគ្រឿងគង់បង្ការចំពោះអាវុធជាវត្ថុ ដែលធ្វើឡើងពីដែក ពីសំណរ ស្ពាន់ លង់ហិន ។

## នេះហៅមហាសំកាំង

នហិចំងំ នហិតំ នប៉ូជីជ្ជិតំ ពុទ្ធចំងំ

ពុទ្ធប៉ូតំ ពុទ្ធប៉ូជ្ជិតំ មោហិចំងំ មោប៉ូតំ

មោប៉ូហិតំ ធាហិចំងំ ធាប៉ូតំ ធាប៉ូហិតំ

យចំងំ យប៉ូតំ យប៉ូហិតំ ។

សំរាប់បិទបាំងប្រាណ បង្កាសាស្ត្រាវុធទាំងពួង តបកុំញ៉ាំបន្ទៃឃ្លោក ផ្លែស្ពឺ កុំជេរម្តាយគេ កុំចង្អុល ឱ្យគេប្រហារខ្លួន ដោយចង់ឱ្យគេកោត គួរកុំអាងអួតឡើយ បើមានអាសន្ន សូមសំបូងសំរូងដល់គុណព្រះ ទាំងប្រាំព្រះអង្គ សូមមកជួយការពារអាត្មា ។

អត្តនោកាយពន្ទនេ មារស្សទេវញ្ច វន្ទិត្វា

ទីឃំនិមិត្វាបរិទិត្វា បព្វតទល្អស្វាហាប់ ។

ពេលមានអាសន្ន គប្បីព័ទ្ធសីមាខ្លួនយើងដោយគាថានេះ ដើម្បីបង្កាសត្រូវចោមព័ទ្ធ ឬសារពើ អាវុធ ចូលមិនដល់ខ្លួនយើងឡើយ ។(សូត្រ៧ចប់)

សេពផ្តុំដុំដី ឬ គ្រួស៨ដុំ ចោលគ្រប់៨ទិស សត្រូវមិនចូលដល់ខ្លួន ។

## យើងគួរធ្វើតាម

១-ថ្ងៃអាទិត្យ រៀបចេញដំណើរ សូមយកទឹកស្របទ្រូងបន្តិចជាមុន ជោគជ័យនៅទិសខាងកើត

២-ថ្ងៃចន្ទ រៀបចេញដំណើរ សូមប្រាសខ្លួនដេកបន្តិចសិន ជោគជ័យនៅទិសខាងលិច ។

៣-ថ្ងៃអង្គារ រៀបចេញដំណើរ សូមរកអ្វីបន្តិចសិន ជោគជ័យនៅទិសខាងត្បូង

៤-ថ្ងៃពុធ រៀបចេញដំណើរ សូមផឹកទឹកបន្តិចសិន ជោគជ័យនៅទិសនិរតី(ខាងត្បូង ឈៀងទៅ លិច)

៥-ថ្ងៃព្រហស្បតិ៍ រៀបចេញដំណើរសូមយកម្សៅលាបមុខ ឬក្រមួន ប្រេងលាបសក់ ជាពិសេស លាបទឹកអប់ ជោគជ័យនៅទិសខាងជើង ។

៦-ថ្ងៃសុក្រ រៀបចេញដំណើរ សូមលាបទឹកអប់នៅទ្រូង និងពោះជាមុនសិន ជោគជ័យនៅទិស ខាងអាគ្នេយ៍ (ខាងកើត ឈៀងខាងត្បូង)

៧-ថ្ងៃសៅរ៍ រៀបចេញដំណើរ សូមធ្វើឫក្សពារជាក្រ ទីក្រទារបន្ទិចសិន (ឬទន្រ្ទាំជើង) ជោគនៅ ទិសពាយ័ព្យ ។

កុំយាត្រាទៅកាន់ទិស

១-ថ្ងៃអាទិត្យ កណ្ឌែស្សក: នៅទិសពាយ័ព្យ

២-ថ្ងៃច័ន្ទ ឧសុភារាជ: បូពា៌

៣-ថ្ងៃអង្គារ រាជសីហ៍ នៅទិសឦសាន

៤-ថ្ងៃពុធ ព្យ័គ្ឃ: ឧត្តរ

៥-ថ្ងៃព្រហស្បតិ៍ មហិង្សា ទក្សិណ

៦-ថ្ងៃសុក្រ កក្កដា បស្ចឹម

៧-ថ្ងៃសៅរ៍ ពាយ័ព្យ មានសួស្តី

និមិត្រគួរដឹង គឺ

មុនចេញដំណើរទៅណាមកណា បើមាននិមិត្រប្លែកកើតឡើងក្នុងអាត្មា គប្បីពិចារណារកហេតុ ផលយ៉ាងនេះ គឺ :

១-បើសត្វធ្លាក់ចំកណ្តាលទីប្រជុំ ប្រែសេចក្តីថា ក្នុងភូមិស្រុករបស់ខ្លួន នឹងមានការគួរឱ្យបារម្ភ

២-បើសត្វធ្លាក់ចំពីមុខ លោកថានឹងបានទទួលជោគជ័យពីកិច្ចការដែលបានធ្វើហើយ ។

៣-បើសត្វធ្លាក់ពីក្រោយខ្នង ច្រើនតែស៊ុនស័យ ធ្លោយថ្លោះការ ចូរប្រយ័ត្នខ្លួន ។

៤-បើធ្លាក់នៅខាងឆ្វេងខ្លួន នឹងបានលាភទ្រព្យរបស់ផ្សេងៗពីគំនិត ឬកិច្ចការរបស់ខ្លួន ។

៥-បើធ្លាក់នៅពីខាងស្តាំ គួរកុំចរលីលាទៅណាឆ្ងាយ មានហេតុពីសត្រូវប៉ងធ្វើឃាដ ។

៦-បើធ្លាក់ចំលើក្បាល នឹងមានការរំលោភមើលងាយពីពួកពាលយង់ឃ្នង ។

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

៧-បើធ្លាក់លើជើង ចេញយាត្រាទៅជាប្រញាប់ នឹងមានគេទន្ទឹងមើលផ្លូវចាំជួបទុក្ខធុរៈ ឬប្រគល់របស់ផ្សេងៗឱ្យដោយសេចក្ដីរលឹកអាល័យ ។

ថ្ងៃដែលមាននាមសត្វទាំង៧ប្រចាំយ៉ាងនេះ សឱ្យឃើញថា យាមមិនឱ្យយាត្រាពានលើទិស ដែលហាម គឺ :

១-អាទិត្យ : កុំយាត្រាទៅខាងទិស ឧត្តរ

២-ច័ន្ទ : ឦសាន

៣-អង្គារ : បូពា

៤-ពុធ : អាគ្នេយ៍

៥-ព្រហស្បតិ៍ : និរតី

៦-សុក្រ : ពាយ័ព្យ

៧-សៅរ៍ : ទក្សិណ

ទិសដែលមានជ័យ

១-អាទិត្យ ចូលទៅកាន់ទិសបូពា មានរិទ្ធិ

២-ច័ន្ទ បស្ចឹម មានតេជៈ

៣-អង្គារ៍ ទក្សិណ មានជ័យ

៤-ពុធ និរតី មានសេរី

៥-ព្រហស្បតិ៍ ឧត្តរ មានលាភ

៦-ថ្ងៃសុក្រ អាគ្នេយ៍ បានសេរីយស

៧-ថ្ងៃសៅរ៍ គជរង្គៈ អាគ្នេយ៍

## ត្រូវដឹងហេតុផលជីពចរត្រង់ ចូរដឹងថា :

ត្របកភ្នែកស្ដាំមានភ្ញៀវយករបស់មកផ្ញើ

ត្របកភ្នែកឆ្វេង ពួកស្រីៗរិះគន់គហានិន្ទាដើម

ក្រោមភ្នែកស្ដាំ ពួកមិត្រនឹងមករកដល់ទីកន្លែង

ក្រោមភ្នែកឆ្វេង នឹងមានរឿងសួរមាត់សួរកថា

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

ច្រមុះ មានគេគុំចាប់ទោសអូសដំណើរ

ត្រចៀកស្តាំ មានគេសរសើរគុណរបស់ខ្លួន

ត្រចៀកឆ្វេង មានគេមកញុះញង់បង្ករឿង

នៅកខាងស្តាំ កូនប្រុសជាទីស្រឡាញ់ផ្ញើរបស់ឱ្យ

នៅកខាងឆ្វេងបើមានកូនស្រីនឹងបានកូនប្រសា

ក្លៀកខាងឆ្វេងស្រីមេម៉ាយផ្តាំផ្ញើកិច្ចការឱ្យដល់

គល់ក្លៀកខាងស្តាំ មានការហ្មងហ្មរកើតឡើងមិនខាន

ដើមទ្រូង ឬគល់ដោះ រឿងចាស់កម្រើកជាថ្មីទៀតហើយ ។

ខ្នង មានគេដឹកនាំឱ្យរកការងារធ្វើ ។

មាត់ខាង (បបូរ) ស្តាំ នឹងបានរបស់បរិភោគយ៉ាងច្រើន ។

បបូរមាត់ខាងឆ្វេង បណ្តាលឱ្យមានគេជជែកគ្នា

គូទ (កំប៉េះ) ស្រីមានចិត្តប្រតិព័ទ្ធគួចមេត្រី

ស្មងជើង កុំឡេះកុំឡោះនឹងស្រីកើតក្តីអាស្រូវ

កំភួនដៃខាងស្តាំ មានគេជួយឈឺឆ្អាលប្រាប់ប្រយោជន៍

កំភួនដៃខាងឆ្វេង គូស្វាមីភរិយាឬគ្រួសារមានវិបត្តិ

កែងដៃខាងស្តាំ បងប្អូនមកពឹងពាក់សូមស្នាក់នៅ

កែងដៃខាងឆ្វេង មិត្តភក្តិមកពីឆ្ងាយមកលេង

បាតដៃខាងស្តាំ នឹងបានកាន់កាប់មុខការជាធំ

បាតដៃខាងឆ្វេង ប្រយ័ត្នក្រែងមានគេប្រុងប្រវ័ញ្ច

ជង្គង់ខាងស្តាំ បានរបស់ដោយមិនបាច់ខ្វល់ខ្វាយច្រើន

ជង្គង់ខាងឆ្វេង មានការផលរមាស់នឹងបក្ខពួកស្រីៗ

ខ្នងជើងខាងឆ្វេង កើតក្តីក្តៅក្រហាយចិត្តត្បិតយកអាសាគេ

ខ្នងជើងខាងស្តាំ មានគេមកនាំឱ្យទៅរកប្រយោជន៍

ដោះទាំងសងខាង មានមិត្តធ្វើធំជួយបំពេញផលផ្សេងៗ

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

ស្មាខាងឆ្វេង មុខជារាល គ្រួសារដោយថៃដន្យ

ស្មាខាងស្តាំ គ្រួសារមូលត្រកូលគ្នាវិញ ជាសុខសាន្ត

ភ្លៅខាងឆ្វេង ប្រយ័ត្នកើតមានរោគសាហាវដល់អាត្មា

ភ្លៅខាងស្តាំ មានគេមកបបួលឱ្យទៅសប្បាយជាមួយគេ

## យល់សប្តិត្រូវអ្នកណា

១-ថ្ងៃអាទិត្យ មិនពិតជាត្រូវលើអ្នកណាទេ

២-ថ្ងៃច័ន្ទ ត្រូវលើញាតិមិត្ត បក្ខពួកប្រុស-ស្រី

៣-ថ្ងៃអង្គារ៍ ត្រូវលើមាតាបិតា ត្រកូលរៀមច្បង

៤-ថ្ងៃពុធ ត្រូវលើប្តីឬប្រពន្ធក្រុមគ្រួសារញាតិពន្ធ

៥-ថ្ងៃព្រហស្បតិ៍ ត្រូវលើគ្រូបាធ្យាយអាចារ្យសមណជី

៦-ថ្ងៃសុក្រ ត្រូវបាវ ព្រាវ សត្វដែលខ្លួនចិញ្ចឹមថែរក្សា

៧-ថ្ងៃសៅរ៍ ត្រូវលើខ្លួនអ្នកយល់សប្តិ .

------------------------ចប់--------------------------